ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

CAMMA MICROFINANCE LIMITED

# របាយការណ៍ប្រចាំឆ្នាំ ២០១០



# មាតិកា

ការពិពណ៌នាអំពី ខេមា ..... ៣
សារពីប្រធានក្រុមប្រឹក្សាភិបាល..... ៧
សារលិខិតពីអគ្គនាយិកា ..... ៩
កម្មសិទ្ធិ និង អភិបាលកិច្ច ..... ១១
    រចនាសម្ព័ន្ធគ្រប់គ្រង..... ១១
    ភាគទុនិក..... ១២
    ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង ..... ១២
របាយការណ៍ក្រុមប្រឹក្សាភិបាល ..... ១៤
ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ..... ១៩
សេចក្ដីប្រកាសរបស់ថ្នាក់ដឹកនាំ..... ២១
របាយការណ៍ហិរញ្ញវត្ថុ..... ២២
    តារាងតុល្យការ..... ២២
    របាយការណ៍លទ្ធផល..... ២៣
    របាយការណ៍ចរន្តសាច់ប្រាក់ ..... ២៤
    របាយការណ៍ចរន្តមូលនិធិម្ចាស់ក្រុមហ៊ុន..... ២៥
កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ..... ២៦

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

## ការពិពណ៌នាអំពីខេមា

### ប្រវត្តខេមា

*ដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ចាំបាច់តម្រូវឲ្យប្រជាជនមានមុខរបរ ប្រកបអាជីវកម្មជាលក្ខណៈគ្រួសារ ឬជាសហគ្រាសធនតូច និងមធ្យម ទៅតាមសមត្ថភាព បច្ចេកទេស និងបទពិសោធន៍របស់ប្រជាជន។ ប៉ុន្តែប្រជាជនតែងជួបបញ្ហាលំបាក ក្នុងការស្វែងរកប្រភពទុន ដើម្បីបង្កើត និងពង្រីកអជីវកម្មរបស់ខ្លួន។ បញ្ហានេះបានធ្វើឲ្យគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ មានការកើនឡើង និងបានផ្តល់ឥណទានប្រមាណជាង ១,២៤៧,៧៧៣លានរៀល (ប្រមាណ ៣០០លានដុល្លារអាមេរិក) ដល់ប្រជាជនប្រមាណ ៨៧៨,៥៥៩នាក់* [1] *។ ទោះជាយ៉ាងនេះក៏ដោយ ក៏វិស័យមីក្រូហិរញ្ញវត្ថុនៅមិនទាន់ អាចបំពេញតំរូវការប្រជាជននៅឡើយ ដោយប្រជាជនដែលនៅក្រោម បន្ទាត់នៃភាពក្រីក្រមានចំនួន ប្រមាណជាង ៤លាននាក់។*

*កត្តានេះហើយបានធ្វើឲ្យភាគទុនិកទាំងអស់ សហការគ្នាបង្កើតគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុថ្មីមួយ ដែលមានឈ្មោះថា* **ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត** *និងមានដើមទុនចុះបញ្ជីចំនួន ២០០,០០០ដុល្លាអាមេរិក ហើយបានចុះបញ្ជីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី ៦ ខែមេសា ឆ្នាំ២០១០ និងបានទទួលអជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១០។ នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១០ ខេមា បានបន្ថែមដើមទុនដល់ ៣៥០,០០០ដុល្លារអាមេរិក។*

---

[1] *របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០០៩ របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា*

## ឈ្មោះនិងអត្តសញ្ញាណខេមា

*ខេមា មានន័យជាភាសាខ្មែរថា "សុខក្សេមក្សាន្ត"។ ភាពសុខក្សេមក្សាន្តនេះ គឺជាកត្តាចំបង ដែលគ្រឹះស្ថានរបស់យើងយកចិត្តទុកដាក់ ដោយហេតុថាសេចក្តីសុខរបស់អតិថិជន គឺជាសេចក្តីសុខរបស់គ្រឹះស្ថាន ហើយវាក៏ជាសេចក្តីសុខរបស់សង្គមជាតិទាំងមូល។*

*អត្តសញ្ញាណរបស់ខេមាត្រូវបានចរិកឡើងដោយ ក្បាលហង្សពណ៌មាស ដែលមានជំពុះពាំគួរស្រូវ នៅក្នុងរង្វង់អក្សរ C តំណាងឲ្យពាក្យ CAMMA ហើយរំលេចដោយពណ៌លឿង ប្រផេះ និងបៃតង។ នៅផ្នែកខាងក្រោមនៃក្បាលហង្សពណ៌មាស មានចរិកអក្សរពណ៌ក្រហមជាភាសាខ្មែរ ខេមា មីក្រូហិរញ្ញវត្ថុ និងភាសាអង់គ្លេសថា CAMMA MICROFINANCE។*

*ក្បាលហង្សពណ៌មាសតំណាងឲ្យប្រាក់កាស និងសក្តានុពលនៃការផ្តល់ឥណទានជូនប្រជាពលរដ្ឋ ដែលធ្វើឲ្យពួកគាត់ទទួលបាននូវទំនុកចិត្ត ។ គួរស្រូវតំណាងឲ្យភោគផលកសិកម្ម និងអាជីវកម្មដ៏សំបូរបែបរបស់ប្រជាពលរដ្ឋតាមរយៈការទទួលសេវាកម្មឥណទានពី ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត។ ពណ៌បៃតងតំណាងឲ្យបរិស្ថានធម្មជាតិ និងភាពលូតលាស់ក្នុងការប្រកបមុខរបរ អាជីវកម្មរបស់អតិថិជន និងគ្រឹះស្ថាន។ ពណ៌លឿងតំណាងឲ្យភាពឆ្នៃប្រឌិត និងសុក្រិតនិច្ឆ័យរបស់បុគ្គលិក។ ពណ៌ប្រផេះស្រាលនៅចន្លោះពណ៌បៃតង និងពណ៌លឿងតំណាងឲ្យទំនាក់ទំនងដ៏ជិតស្និទ្ធរវាងគ្រឹះស្ថាន និងអតិថិជន។ ពណ៌ក្រហមតំណាងឲ្យភាពអង់អាចក្លាហានរបស់បុគ្គលិក ក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដើម្បីធ្វើឲ្យជីវភាពរបស់អតិថិជនមានភាពថ្កុំថ្កើនរុងរឿង។*

## ទស្សនៈវិស័យ

*ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏មានទំនុកចិត្តមួយ ដែលផ្តល់ឱកាសឲ្យប្រជាពលរដ្ឋកម្ពុជាក្នុងការកែលំអរជីវភាពរស់នៅតាមរយៈការទទួលយកសេវាឥណទាន ពីខេមា មីក្រូហិរញ្ញវត្ថុ។*

## បេសកកម្ម

*ផ្តល់សេវាមីក្រូហិរញ្ញវត្ថុដ៏ធំទូលាយដល់ សហគ្រិនខ្នាតតូច និងមធ្យម ដែលជា ប្រជាកសិករ សិប្បករ និងពាណិជ្ជករ ប្រកបដោយសមត្ថភាព និរន្តរភាព និងធានាបាននូវអត្ថប្រយោជន៍ខ្ពស់ជូនភាគទុនិក បុគ្គលិក និងសង្គមជាតិទាំងមូល។*

# ទីផ្សារគោលដៅ

ទិផ្សារគោលដៅរបស់ខេមា គឺជាប្រជាពលរដ្ឋខ្មែរដែលមានគោលបំណងធ្វើជាសហគ្រិនក្នុងការពង្រីក ឬបង្កើតសហគ្រាសធុនតូច និងមធ្យមក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ចជាតិ។






# សេវាកម្ម

យោងទៅលើតម្រូវការផ្សេងៗគ្នារបស់ប្រជាជនទៅតាមតំបន់នីមួយៗ សេវាឥណទានត្រូវបានបែងចែកជាពីរប្រភេទ៖ សេវាឥណទានមានលក្ខណៈជាក្រុមធានា និងសេវាឥណទានឯកត្តជន។

## ឥណទានក្រុមធានា

ឥណទានប្រភេទនេះ គឺផ្តល់ជូនប្រជាជន អតិថិជនដែលមានកំរិតជីវភាពទាប ឬទាបបំផុតហើយមានមុខរបរជាលក្ខណៈកសិកម្មដូចជា ធ្វើស្រែចំការ ចិញ្ចឹមសត្វ និងជំនួញតូចតាច ដែលទាក់ទងនឹងវិស័យកសិកម្មជាពិសេស។ ក្រុមធានាត្រូវមានសមាជិកពី ២នាក់ ទៅ៥នាក់ និងដឹកនាំដោយប្រធានក្រុមម្នាក់។ ក្រុមធានានេះត្រូវបានចែកចេញជាពីប្រភេទទៀតគឺៈ ក្រុមធានាដែលមានទ្រព្យដាក់ធានា និងក្រុមធានាដែលគ្មានទ្រព្យដាក់ធានា។

| ក្រុមធានាដែលមានទ្រព្យដាក់ធានា | | | |
|---|---|---|---|
| កម្រិតកម្ចី | វគ្គ | អត្រាការប្រាក់ | រយៈពេល |
| ២០០,០០០៛-១,០០០,០០០៛ | វគ្គទី១ | ៤% | ៦ខែ ដល់ ១២ខែ |
| ១,១០០,០០០៛-១,៥០០,០០០៛ | វគ្គទី២ | ៣.៥% | ៦ខែ ដល់ ១២ខែ |
| ក្រុមធានាដែលគ្មានទ្រព្យដាក់ធានា | | | |
| កម្រិតកម្ចី | វគ្គ | ការប្រាក់ | រយៈពេល |
| ២០០,០០០៛-៤០០,០០០៛ | វគ្គទី១ | ៤% | ៦ខែ ដល់ ១២ខែ |
| ៤១០,០០០៛- ៦០០,០០០៛ | វគ្គទី២ | ៣.៥% | ៦ខែ ដល់ ១២ខែ |
| ៦១០,០០០៛-១,០០០,០០០៛ | វគ្គទី៣ | ៣% | ៦ខែ ដល់ ១២ខែ |

## ឥណទានឯកត្តជន

| កម្រិតកម្ចី | អត្រាការប្រាក់ | រយៈពេល |
|---|---|---|
| ១០០$ - ១,០០០$ | ៣% | ៦ខែ ដល់ ១២ខែ |
| ១០០១$ - ២,៥០០$ | ២.៥% | ១២ខែ ដល់ ២៤ខែ |
| ២៥០០$ - ៤,០០០$ | ២.៣% | ១២ខែ ដល់ ២៤ខែ |
| ៤០០១$ - ៧,៥០០$ | ២% | ១២ខែ ដល់ ២៤ខែ |
| ៧,៥០១$ - ១០,០០០$ | ១.៩% | ១២ខែ ដល់ ២៤ខែ |

# សារពីប្រធានក្រុមប្រឹក្សាភិបាល

ឆ្នាំ២០១០ គឺជាឆ្នាំដំបូងដែលខេមាចាប់ផ្តើមធ្វើប្រតិបត្តិការ ហើយក៏ជាឆ្នាំដែលសេដ្ឋកិច្ចជាតិចាប់ផ្តើមលូតលាស់បន្តិចវិញ បន្ទាប់ពីរងឥទ្ធិពលនៃវិបត្តសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០០៨។ នៅក្នុងឆ្នាំ២០១០នេះ សេដ្ឋកិច្ចជាតិកើនឡើង ៥% ខ្ពស់ជាងការរំពឹងទុក ដោយហេតុថា វិស័យទេសចរណ៍កើនឡើង ១០% វិស័យវាយនភ័ណ្ឌ ១៥.៥% វិស័យវិនិយោគផ្ទាល់បរទេស ៨.១% និង វិស័យកសិកម្ម ៥%។ លើសពីនេះទៅទៀត វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ មានការរីកចំរើនគួរឲ្យកត់សំគាល់។ នៅក្នុងឆ្នាំនេះ ដែរមានធនាគារធំៗ៣ បានចូលមកវិនិយោគនៅកម្ពុជា គឺធនាគា CIMB ធនាគាចិន និងធនាគារកសិកម្ម និងអភិវឌ្ឍជនបទវៀតណាមសាខាកម្ពុជា [2] ។ ចំណែកឯគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអជ្ញាប័ណ្ណ បានកើនឡើង ៥ស្ថាប័នបន្ថែមទៀត ក្នុងនោះមានខេមា មីក្រូហិរញ្ញវត្ថុ លីមីធីតដែលទទួលបានអជ្ញាប័ណ្ណ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០។

មេរៀនពីវិបត្តសេដ្ឋកិច្ចពិភពលោកបានធ្វើឲ្យ ខេមា ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មី មានការប្រុងប្រយ័ត្នក្នុងការធ្វើប្រតិបត្តិការរបស់ខ្លួន។ យើងជ្រើសរើសយកយុទ្ធសាស្រ្តបង្កើនគុណភាពឥណទាន ជាជាងបង្កើនបរិមាណនៃឥណទាន ឬទំហំនៃសំពាធឥណទាន។ ភ្នាក់ងារឥណទានរបស់យើងធ្វើការវាយតម្លៃ និងតាមដានយ៉ាងល្អិតល្អន់ចំពោះ ឥណទាននីមួយៗ។ ពួកគេមិនត្រឹមតែជាអ្នកវាយតម្លៃឥណទានប៉ុណ្ណោះទេ តែក៏ជាអ្នកពិគ្រោះយោបល់ជូនអតិថិជន ក្នុងការប្រើប្រាស់ទុនកម្ចីឲ្យចំគោលដៅ ដើម្បីភាពរីកចំរើននៃអាជីវកម្មរបស់អតិថិជនក៏ដូចជាភាពរីកចំរើននៃសេដ្ឋកិច្ចគ្រួសារនិងសង្គមជាតិ ។ ដូច្នេះបុគ្គលិក គឺជាធនធានដ៏មានតម្លៃរបស់ខេមា ដែលយើងត្រូវតែបន្តយកចិត្តទុកដាក់អភិវឌ្ឍដើម្បីជានាបាននូវសមត្ថភាព និងសេវាដ៏ប្រសើរជូនអតិថិជន។

តាងនាមឲ្យក្រុមប្រឹក្សាភិបាលរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ខេមា ដែលខិតខំតស៊ូជាមួយខេមា ក្នុងកាលៈទេសៈដ៏លំបាកនៃការចាប់ផ្តើមដំបូងនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់ធនាគារជាតិនៃកម្ពុជាចំពោះការ ណែរនាំគាំទ្រ និងយោគយល់ចំពោះគ្រឹះស្ថានយើងខ្ញុំ ដែលទើបនឹងចាប់ផ្តើមធ្វើប្រតិបត្តការណ៍។ ជាចុងក្រោយ

[2] ប្រសាសន៍របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលនៃធនាគាជាតិនៃកម្ពុជា ក្នុងកិច្ចប្រជុំ SEACEN EXCO ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១១

ខ្ញុំសូមអគុណ ដល់ភាគទុនិកទាំងអស់ដែលជឿជាក់លើប្រតិបត្តិការរបស់ខេមា ក្នុងការផ្តល់ឥណទានជូនប្រជាពលរដ្ឋ ក៏ដូចជាចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ដោយក្តីគោរពរាប់អានដ៏ស្មោះស្ម័គ្រ

ប្រធានក្រុមប្រឹក្សាភិបាល

បែន សុនសម័យ

# សារលិខិតពីអគ្គនាយិកា

*ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត បានចាប់ផ្តើមធ្វើប្រតិបត្តការរបស់ខ្លួន នៅពាក់កណ្តាលខែសីហា ឆ្នាំ២០១០។ គោលបំណងចំបងរបស់ខេមា គឺផ្តល់ឱកាសឲ្យប្រជាពលរដ្ឋកម្ពុជាមានលទ្ធិភាពធ្វើជាសហគ្រិន ក្នុងការបង្កើត អាជីវកម្មដែលមានលក្ខណៈជាគ្រួសារ ឬជាសហគ្រាសធន់តូចនិងមធ្យម ក្នុងគ្រប់វិស័យ នៃសេដ្ឋកិច្ចជាតិ ដើម្បីប្រែក្លាយជីវភាពរស់នៅឲ្យប្រសើរឡើង និងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។*

*ក្នុងរយៈពេលប្រាំខែបន្ទាប់ពីគ្រឹះស្ថានបានទទួលអាជ្ញាប័ណ្ណមក គ្រឹះស្ថានបានធ្វើប្រតិបត្តិការឥណទាន និងបានផ្តល់ឥណទានដល់ប្រជាជន ដែលជាកសិករ និង អាជីវករ ដែលរស់នៅក្នុងក្រុងភ្នំពេញ ចំនួន ២៣គ្រួសារ និងនៅខេត្តកណ្តាល ១៧ គ្រួសារ សរុបជាទឹកប្រាក់ចំនួន ១៤០,៣៣២ដុល្លាអាមេរិក ក្នុងនោះមានអតិថិជនជាស្ត្រី ១៦នាក់ និង បុរស ២៤នាក់ ។ សមតុល្យឥណទានរបស់ខេមាកើនឡើងពី ២,០០០ដុល្លារអាមេរិក ក្នុងខែសីហា ដល់ ១៤០,៣៣២ដុល្លាអាមេរិក ក្នុងខែធ្នូនៃឆ្នាំ២០១០។ ទោះជាសមតុល្យឥណទាននេះមានការកើនឡើងគួរឲ្យកត់សំគាល់ក៏ដោយ ក៏ប្រាក់ចំណេញក្រោយពេលបង់ពន្ធរបស់ ខេមា នៅបង្ហាញសញ្ញាអវិជ្ជមាន។*

*បញ្ហាខាងលើនេះត្រូវបានដោះស្រាយនៅក្នុងឆ្នាំ២០១១នេះ ដោយបង្កើនទូវសក្តានុពលនៃការផ្តល់ឥណទានតាមបែបផែនពង្រីកតំបន់ប្រតិបត្តិការឲ្យបានធំទូលាយគ្របដណ្តប់បណ្តារខណ្ឌទាំងអស់ក្នុងរាជធានីភ្នំពេញ និងខេត្តមួយចំនួនដូចជា កណ្តាល តាកែវ និង កំពង់ស្ពឺ។ ផ្តល់សេវាឥណទានជូន ប្រជាពលរដ្ឋឲ្យបានឆាប់រហ័ស។ បន្តបណ្តុះបណ្តាលមន្ត្រីឥណទាន ដើម្បីទទួលបានគុណភាព និងប្រសិទ្ធិភាពនៃ ការងារ។*

*យុទ្ធសាស្ត្រទាំងនេះ តម្រូវឲ្យយើងមានប្រភពទុនដែលមានតម្លៃថោក ។ ឆ្លើយតបនិងតម្រូវការនេះ ភាគទុនិកទាំងអស់បន្តផ្តល់ដើមទុនបន្ថែមទៀត ។ ជាក់ស្តែងនៅចុងឆ្នាំ២០១០ ភាគទុនិកបានបន្ថែមដើមទុនពី ២០០,០០០ដុល្លារអាមេរិក ដល់ ៣៥០,០០០ដុល្លារអាមរិក។ មិនតែប៉ុណ្ណោះ ខេមា បាននឹងកំពុងខិតខំស្វែងរកប្រភពកម្ចីផ្សេងទៀតដើម្បីបន្តនិរន្តភាពហិរញ្ញវត្ថុ និងពង្រីកវិលាសភាពនៃប្រតិបត្តិការរបស់ខ្លួន។*

*យើងខ្ញុំជឿជាក់ថា ការខិតខំប្រឹងប្រែងនេះ ការយកចិត្តទុកដាក់ និងការគាំទ្រពីសំណាក់ អតិថិជន ភាគទុនិក បុគ្គលិក មន្ត្រីរាជការទាំងអស់ នឹងធ្វើឲ្យ ខេមា ទទួលបានផ្លែផ្កាជា វិជ្ជមាននៅពាក់កណ្តាលឆ្នាំ២០១១នេះ។*

តាងនាមឲ្យភាគទុនិកទាំងអស់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ មន្ត្រី បុគ្គលិក នៃធនាគារជាតិនៃកម្ពុជា បណ្តាលក្រសួង មន្ទីរនានាដែលពាក់ព័ន្ធ និងអតិថិជនទាំងអស់របស់ខេមា។ ការយកចិត្តទុកដាក់ ការអត់ឱន ការយោគយល់ ជំនួយ និងការសហការរបស់ អ្នកទាំងអស់គ្នា បានធ្វើឲ្យគ្រឹះស្ថានយើងខ្ញុំអាចក្រោកឈរឡើង និងបោះជំហ៊ានទៅមុខជាមួយបណ្តាលគូរប្រកួតប្រជែង។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអរគុណជាអនេកជូនចំពោះ បុគ្គលិករបស់ខេមាទាំងអស់ ដែលបានខិតខំប្រឹងប្រែង អស់ពីកំលាំងកាយចិត្ត ក្នុងការជួយស្ថាបនាគ្រឹះស្ថាន និងជាសរសរទ្រូងដ៏រឹងមាំរបស់ គ្រឹះស្ថាន។

ដោយក្តីគោរពរាប់អានដ៏ស្មោះស្ម័គ្រ

អគ្គនាយិកា

ឱត នីតា

# កម្មសិទ្ធិភាព និង អភិបាលកិច្ច

## រចនាសម្ព័ន្ធគ្រប់គ្រង



## ភាគទុនិក

គិតមកត្រឹមដំណាច់ឆ្នាំ២០១០ ខេមា មានភាគហ៊ុនដើមទុនសរុបចំនួន ៣៥០,០០០ដុល្លារអាមេរិក ដែលចូលរួមដោយភាគទុនិកចំនួន ២រូប គឺ លោកជំទាវ អ៊ូ សាន និង លោកស្រី ឌិត នីតា។

| ភាគទុនិក | វិនិយោគជាដុល្លា | ភាគរយនៃដើមទុន |
|---|---|---|
| លោកជំទាវ អ៊ូ សាន | ២១០,០០០ | ៦០% |
| លោកស្រី ឌិត នីតា | ១៤០,០០០ | ៤០% |
| សរុប | ៣៥០,០០០ | ១០០% |

## ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង

**ឯកឧត្តម បែន សុនសម័យ** ប្រធានក្រុមប្រឹក្សាភិបាល

- បរិញ្ញាបត្រ នីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ក្រុងភ្នំពេញ កម្ពុជា
- JD from George Mason University Washington D.C (School of Law)
- មេធាវីសារការី ប្រចាំព្រះរាជាណាចក្រកម្ពុជា
- មានបទពិសោធន៍ការងារ ២០ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងផ្នែកច្បាប់ និងសង្គម

**លោកស្រី ខាត់ សុខគាន** អនុប្រធានក្រុមប្រឹក្សាភិបាល

- Master of Finance, Panassastra University of Cambodia (PUC)
- Bachelor of Finance and Banking, National University of Management
- Bachelor of Management Information System, National University of Management
- ABAC Accountant – Delegation of the European Union in Cambodia
- មានបទពិសោធន៍ការងារ ៥ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

**លោកស្រី សាយ ចាន់ណាក់** *សមាជិកក្រុមប្រឹក្សាភិបាល*

- Bachelor of Management Information System – National University of Management
- Bachelor of Hotel and Tourism – National University of Management
- *មានបទពិសោធន៍ការងារ ៥ឆ្នាំ ក្នុងព្រះរាជាណាចក្រកម្ពុជា ផ្នែក* Public Relation, Marketing and Finance

**ឱត នីតា** *អគ្គនាយិកា*

- Master of Financial Management – Australia National University
- Bachelor of Commerce with honor – Australia National University
- Bachelor of Commerce major in Accounting and Finance – Australia National University
- *មានបទពិសោធន៍ការងារ ២ឆ្នាំ ក្នុងព្រះរាជាណាចក្រកម្ពុជា ផ្នែកគ្រប់គ្រងអាជីវកម្ម*

# របាយការណ៍ក្រុមប្រឹក្សាភិបាល

*ក្រុមប្រឹក្សាភិបាលមានកិត្តិយសដាក់ជូនពិនិត្យនូវរបាយការណ៍ប្រចាំឆ្នាំ និងរបាយការហិរញ្ញវត្ថុ របស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត (លំដាប់ទៅនេះហៅកាត់ថា ខេមា) សម្រាប់ការិបរិច្ឆេទ ចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១០ (ថ្ងៃដែល ខេមា ចាប់ផ្តើមប្រតិបត្តិការដំបូង) រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១០។*

## សកម្មភាពចំបង

*ខេមា មានសកម្មភាពចំបងនៅព្រះរាជាណាចក្រកម្ពុជាក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ ការផ្តល់សេវាកម្ម ហិរញ្ញវត្ថុនេះ រួមមានការផ្តល់សេវាឥណទានសម្រាប់ការបង្កើត និងពង្រីកមុខរបបរបស់ប្រជាជនកម្ពុជាគ្រប់ មជ្ឈដ្ឋាន។*

## លទ្ធផលសង្ខេប

*លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ដូចមានខាងក្រោម៖*

| | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១០<br>មិនទាន់បានធ្វើសវនកម្ម | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | 324,091 | 1,313,543 |
| ឥណទាន និង បុរេប្រទានដល់អតិថិជនសុទ្ធ | 142,036 | 568,765 |
| ទ្រព្យអកម្ម | 53 | 214 |
| ដើមទុន និងភាគហ៊ុនចុះបញ្ជី | 350,000 | 1,418,550 |
| មូលនិធិភាគទុនិក | 350,000 | 1,418,550 |
| ខាតមុនបង់ពន្ធ | (25,927) | (105,082) |
| សំវិធានធនពន្ធ | (35) | (141) |
| លទ្ធផលខាតបង្គរ | (25,962) | (105,223) |

## លាភការសម្រាប់ភាគទុនិក

ខេមា ពុំមានលាភការលើភាគហ៊ុនដែលបានប្រកាស ឬបានបង់នៅក្នុងឆ្នាំនេះទេ។

## ដើមទុន

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ខេមា មានដើមទុនចុះបញ្ជីចំនួន ២០០,០០០.០០ដុល្លារ។ នៅ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ខេមា បានបន្ថែមដើមទុនចំនួន ១៥០,០០០ដុល្លារ។ ដូច្នេះសម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ខេមា មានដើមទុនសរុបទាំងអស់ចំនួន ៣៥០,០០០ដុល្លារ។

## ប្រាក់តំកល់ធានាដើមទុន

ប្រាក់តំកល់តាមច្បាប់នៅធនាគារជាតិ របស់ ខេមា បានកើនពី ១០,០០០ដុល្លារ ទៅ ១៧,៥០០ដុល្លារ នៅការិយបរិច្ឆេទ ថ្ងៃទី៣១ខែធ្នូឆ្នាំ២០១០។

# បំណុលជាប់សង្ស័យ និងពិបាកទារ

មកដល់ថ្ងៃចេញរបាយការណ៍នេះខេមា ពុំមានបំណុលសង្ស័យគួរ ឬពិបាកទារឡើយ ។ ដូចនេះ ក្នុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០នេះ ខេមា មិនមានទឹកប្រាក់សំវិធានធនចំពោះបំណុលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។

# ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្ត លើកលែងបំណុលចេញ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលមានតម្លៃមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

# វិធីសាស្ត្រនៃការវាយតម្លៃ

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ដែលធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

# បំណុលយថាហេតុ និងទ្រព្យអកម្មផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះពុំមាន៖

- ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងថ្ងៃចុងការិយបរិច្ឆេទសម្រាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ
- បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមាន

*បំណុលយថាហេតុ ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវមានកាតព្វកិច្ចអនុវត្ត ឬអាចនឹងត្រូវមានកាតព្វកិច្ចអនុវត្តក្នុងរយៈពេល ១២ខែ បន្ទាប់ពីថ្ងៃបញ្ចប់បញ្ជីនៃការិយបរិច្ឆេទ ដែលនឹងមានការប៉ះពាល់ ឬនឹងមានការប៉ះពាល់យ៉ាងសំខាន់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់។*

## ការផ្លាស់ប្តូរនៃហេតុការណ៍

*នាថ្ងៃចេញរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយកាណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។*

## ប្រការមិនប្រក្រតី

*តាមមតិរបស់ក្រុមប្រឹក្សាភិបាលលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ ខេមា ក្នុងការិយបរិច្ឆេទនេះមិនមានការប៉ះពាល់សំខាន់ដោយប្រការ ឬកិច្ចការជំនួញ ឬព្រឹត្តការណ៍ណាមួយដែលមានលក្ខណៈ នឹងមិនជម្មតានោះទេ។*

*ក្រុមប្រឹក្សាក៏មានយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រត្តិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈសំខាន់ និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ ខេមាក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។*

## សមាជិកក្រុមប្រឹក្សាភិបាល

*សមាជិកក្រុមប្រឹក្សាភិបាលរបស់ ខេមា មានសមាសភាពដូចតទៅ:*

| | | |
|---|---|---|
| **ឯកឧត្តម បែន សុនសម័យ** | *ប្រធាន* | *(តែងតាំងក្នុងលក្ខន្តិកៈ)* |
| **លោកស្រី ខាត់ សុខគាន** | *អនុប្រធាន* | *(តែងតាំងក្នុងលក្ខន្តិកៈ)* |
| **លោកស្រី សាយ ចាន់ណាក់** | *សមាជិក* | *(តែងតាំងក្នុងលក្ខន្តិកៈ)* |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មកដល់ការិយបរិច្ឆេទនេះ ខេមា ពុំមានការព្រមព្រៀងណាមួយដែលចូលរួមជាគូរភាគីក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សា របស់ខេមាដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយការទិញយកភាគហ៊ុន ឬ លិខិតបំណុល ពីខេមា ឬ អង្គភាពផ្សេងដទៃទៀតទេ។ ក្រុមប្រឹក្សាភិបាលបានទទួលលាភការផ្សេងៗ ដូចមានចែងក្នុងគោលការណ៍ផ្ទៃក្នុងរបស់ខេមា តាមរយៈការប្រជុំផ្សេងៗទាក់ទងនឹងការអភិវឌ្ឍន៍ និងការផ្លាស់ប្តូររបស់ខេមា ដោយគិតជាចំនួនដងនៃការប្រជុំ ។

## តម្លៃប្រៀបធៀប

របាយការណ៍ហិរញ្ញវត្ថុនេះជាសេចក្តីរាយការណ៍មួយដែលបានរៀបចំឡើងចាត់តាំងពីក្រុមហ៊ុនមានដំណើរការអាជីវកម្មដូច្នេះ របាយការណ៍នេះពុំមានតួលេខប្រៀបធៀបទេ។

# ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈកិច្ចធ្វើការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញពីទិដ្ឋភាពពិតប្រាកដរបស់ខេមា និងលទ្ធផលនៃដំណើរការអាជីវកម្ម និងស្ថានភាព ចរន្តសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបិទបញ្ជី។ ការរៀបចំរបាយការណ៍នេះ តំរូវឲ្យក្រុមប្រឹក្សាភិបាលៈ

(១) អនុវត្តន៍នូវគោលការណ៍គណនេយ្យសមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍គោលការណ៍ទាំងនេះជានិច្ចកាល។

(២) គោរពតាមគោលការណ៍គណនេយ្យ និងគោលការណ៍ណែនាំ ដែលតំរូវដោយធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រសិនបើការស្វែងរកទិដ្ឋភាពពិតប្រាកដ តំរូវឲ្យប្រើវិធានដទៃទៀត ដែលខុសពីវិធានមុនៗ វិធានថ្មីនេះត្រូវបានបង្ហាញ និងពន្យល់ឲ្យ បានច្បាស់លាស់ និងកំណត់បរិមាណនៃការប្រែប្រួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(៣) រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើនិរន្តរ៍ភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្និដ្ឋានថា ខេមានឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្ម របស់ខ្លួននាពេលអនាគត ។

(៥) ត្រួតពិនិត្យ និងដឹកនាំខេមាឲ្យមានប្រសិទ្ធិភាពលើរាល់ការសំរេច ដែលមានសារៈសំខាន់ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ខេមា ហើយត្រូវប្រាកដថាកិច្ចសន្យានោះត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលជានាអះអាងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុថា ខេមាបានអនុវត្តន៍នូវរាល់ តំរូវការដូចមានចែងខាងលើ ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលដោយៈ

បែន សុនសម័យ

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី ខែមេសា ឆ្នាំ ២០១១

# សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំ

យើងខ្ញុំជាអភិបាល និង អគ្គនាយិកា របស់គ្រឹះស្ថានខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត សូមប្រកាសថាតាមយោបល់របស់យើងខ្ញុំ:

(១) លទ្ធផលនៃប្រតិបត្តិការរបស់ខេមា សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១០ ដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០ មិនមានការប៉ះពាល់យ៉ាងសំខាន់ដោយប្រការណាមួយ ឬ កិច្ចការជំនួញ និងព្រឹត្តិការណ៍មួយនោះ ក៏ពុំបានកើតមានឡើងក្នុងចន្លោះពេល ចាប់ពីថ្ងៃបិទការិយបរិច្ឆេទមកទល់នឹងថ្ងៃចេញរបាយការណ៍នេះទេ ក្រៅពីអ្វីដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(២) របាយការហិរញ្ញវត្ថុរបស់ខេមា ដែលមានភ្ជាប់ត្រូវបានរៀបចំឡើងដើម្បីបង្ហាញនូវទិដ្ឋភាព ពិតប្រាកដនៃកិច្ចការរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០ និងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពចរន្តសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃខាងលើ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលដោយ:

| | |
|---|---|
| បែន សុនសម័យ | ឌិត នីតា |
| ប្រធានក្រុមប្រឹក្សាភិបាល | អគ្គនាយិកា |
| ថ្ងៃទី ខែមេសា ឆ្នាំ ២០១១ | ថ្ងៃទី ខែមេសា ឆ្នាំ ២០១១ |

# របាយការណ៍ហិរញ្ញវត្ថុ (មិនទាន់បានធ្វើសវនកម្ម)

## តារាងតុល្យការ

### ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០

| | | ២០១០ | |
|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក USD | ពាន់រៀល KHR'000 |
| **ទ្រព្យសកម្ម** | | | |
| *សាច់ប្រាក់* | | 697 | 2,825 |
| *សមលុត្យជាមួយធនាគារជាតិ* | 4 | 160,100 | 648,885 |
| *សមលុត្យជាមួយធនាគារក្នុងស្រុក* | 5 | 4,134 | 16,755 |
| *ការឲ្យខ្ចីចង់ការ និងបុរេប្រទាន* | 6 | 140,332 | 568,766 |
| *គណនីត្រូវទទួលផ្សេងទៀត* | 7 | 7,363 | 29,840 |
| *អចលនទ្រព្យ* | 8 | 11,466 | 46,473 |
| **ទ្រព្យសកម្មសរុប** | | **324,092** | **1,313,544** |
| | | | |
| **ទ្រព្យអកម្ម និង មូលនិធិម្ចាស់ហ៊ុន** | | | |
| **ទ្រព្យអកម្ម** | | | |
| *បំណុលផ្សេងៗ* | 9 | 41 | 165 |
| *សំវិធានធនលើពន្ធ* | 10 | 13 | 52 |
| **ទ្រព្យអកម្មសរុប** | | **54** | **217** |
| **មូលនិធិម្ចាស់ហ៊ុន** | | | |
| *ដើមទុន* | 11 | 350,000.00 | 1,418,550 |
| *លទ្ធផលខាតបង្គរ* | | (25,962) | (105,223) |
| **សរុបមូលនិធិម្ចាស់ហ៊ុន** | | **324,038** | **1,313,327** |
| **សរុបទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | **324,092** | **1,313,544** |

## **របាយការណ៍លទ្ធផល**

### **ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០**

| | | ២០១០ | |
|---|---|---|---|
| | **កំណត់សំគាល់** | **ដុល្លារអាមេរិក** USD | **ពាន់រៀល** KHR'000 |
| ចំណូលពីការប្រាក់ | 12 | 5,045 | 20,447 |
| ចំណាយលើការប្រាក់ | | - | - |
| **ចំណូលពីការប្រាក់សុទ្ធ** | | **5,045** | **20,447** |
| | | | |
| ចំណូលក្រៅពីការប្រាក់ | | 257 | 1,041 |
| ចំណាយក្រៅពីការប្រាក់ | | (90) | (365) |
| បៀវត្ស និងសាហ៊ុយបុគ្គលិកដ៏ទៃទៀត | 13 | (10,420) | (42,234) |
| រំលោះលើសំភារ:បរិក្ខា | 8 | (1,396) | (5,657) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | 14 | (19,323) | (78,314) |
| **លទ្ធផលពីប្រតបត្តការ** | | **(25,927)** | **(105,081)** |
| | | | |
| សំវិធានធនសម្រាប់ឥណទានអាចបាត់បង់ | | - | - |
| លទ្ធផលមុនបង់ពន្ធ | | **(25,927)** | **(105,082)** |
| សំវិធានធនពន្ធ | 10 | (35) | (141) |
| **លទ្ធផលក្រោយបង់ពន្ធ** | | **(25,962)** | **(105,223)** |
| | | | |

# របាយការណ៍ចរន្តសាច់ប្រាក់

## ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០

| | | ២០១០ | |
|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក USD | ពាន់រៀល KHR'000 |
| **ចរន្តសាច់ប្រាក់ពីសកម្មភាពប្រតិបត្តការអាជីវកម្ម** | | | |
| *លទ្ធផលចំណេញខាតក្នុងប្រតិបត្តិការអាជីវកម្ម* | | (25,962) | (105,223) |
| *សំវិធានធនពន្ធ* | | - | - |
| *រំលស់លើអចលនទ្រព្យរូបីយ* | | 1,083 | 4,390 |
| *រំលស់លើអចលនទ្រព្យអរូបីយ* | | 313 | 1,267 |
| | | (24,565) | (99,565) |
| *ការឲ្យខ្ចីចងការ និងបុរេប្រទាន* | | (142,036) | (575,672) |
| *ប្រាក់តំកល់តាមច្បាប់នៅធនាគារជាតិ* | | (17,500) | (70928) |
| *សមតុល្យនៅធនាគារជាតិនៃកម្ពុជា* | | 142,600 | 577,958 |
| *សមតុល្យនៅធនាគារផ្សេងៗ* | | 4,134 | 16,755 |
| *ទ្រព្យសកម្មផ្សេងៗ* | | (1458) | (5,911) |
| *ទ្រព្យអកម្មផ្សេង ៗ* | | 54 | 214 |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តការអាជីវកម្ម** | | (185,507) | (751,860) |
| | | | |
| **ចរន្តសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| *ទិញសំភារៈការិយាល័យ និងបរិក្ខា* | | (9,862) | (39,971) |
| *ទិញទ្រព្យអរូបីយ (ប្រព័ន្ធ MBWin)* | | (3,000) | (17,023) |
| *ប្រាក់កក់ ឬ ប្រាក់បង់មុនផ្សេងៗ (ឈ្នួលផ្ទះ និងកក់ទូរស័ព្ទ)* | | (4,200) | (17,023) |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងការវិនិយោគ** | | (17,062) | (69,152) |
| | | | |
| **សាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ** | | | |
| *ទទួលបានហិរញ្ញប្បទានផ្សេងៗ* | | - | - |
| *ការបែងចែកភាគលាភ* | | - | - |

| | | |
|---|---|---|
| *មូលនិធិម្ចាស់ហ៊ុន* | 350,000 | 1,418,550 |
| **សាច់ប្រាក់សុទ្ធបានពីសកម្មហិរញ្ញវត្ថុ** | 350,000 | 1,418,550 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅចុងការិបរិយច្ឆេទ** ( **ពាន់រៀល**) | 147,431 | 597,537 |

# របាយការណ៍ចរន្តមូលនិធិម្ចាស់ហ៊ុន

## ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០

| | **ដុល្លាអាមេរិក** USD | | | **ពាន់រៀល** KHR'000 |
|---|---|---|---|---|
| | **ដើមទុន** | **លទ្ធផលខាតបង្គរ** | **សរុប** | |
| *សមតុល្យថ្ងៃទី ២៩ ខែ កក្កដា ២០១០* | 200,000.00 | - | 200,000.00 | 810,600 |
| *បង្កើនដើមទុនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១០* | 150,000.00 | - | 150,000.00 | 607,950 |
| *លទ្ធផលនៃការិយបរិច្ឆេទ* | - | (25,962) | (25,962) | (105,223) |
| *សមតុល្យថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំ ២០១០* | **350,000.00** | **(25,962)** | **324,038** | **1,313,327** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ

**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០**

## ១.ពត៌មានទូទៅ

**ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត** *(លំដាប់ទៅនេះហៅកាត់ថា "**ខេមា**" ) ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ដែលបានបង្កើតឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិទាំងឡាយរបស់ធនាគារជាតិ នៃកម្ពុជា។ ខេមាបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៅថ្ងៃទី ០៦ខែមេសា ឆ្នាំ២០១០ និងបានទទួល អជ្ញាប័ណ្ណប្រកបអាជីវកម្ម ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១០។*

*ក្រោមក្របខ័ណ្ឌនៃអជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ ខេមា បានទទួលសិទ្ធិក្នុងការផ្តល់ឥណទានដល់ប្រជាជនកម្ពុជាទូទៅ ទាំងអ្នកទើបបង្កើតមុខរបរ និងអ្នកពង្រីកមុខរបរថ្មី ពិសេសសហគ្រាសធនតូច និងមធ្យមដែលមានប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។*

*ខេមា ប្រកបអាជីវកម្មនៅទីតាំងតែមួយគត់ដែលមានអាស័យដ្ឋានផ្ទះលេខ ៤៩ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងមាននិយោជិតចំនួន ១១ នាក់ និង ក្រុមប្រឹក្សា ចំនួន០៣ រូប នាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១០។*

## ២.មូលដ្ឋាននៃការរៀបចំ

*របាយការណ៍ហិរញ្ញវត្ថុរបស់ ខេមា ត្រូវបានរៀបចំឡើងតាមសម្មតិកម្មនៃតម្លៃដើម ដោយអនុលោមទៅតាម គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ស្តង់ដារគណនេយ្យកម្ពុជា និងទំនៀមទំលាប់នៃឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ។ គោលការណ៍ទាំងនេះតម្រូវឲ្យវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ដោយប្រើតម្លៃយោងដោយមានការកាត់បន្ថយសំវិធានធនសម្រាប់ការថយចុះតម្លៃ។*

## ៣.គោលការណ៍គណនេយ្យសំខាន់ៗ

**(ក) ប្រតិបត្តិការជារូបិយបណ្ណ័បរទេស**

ទ្រព្យសកម្ម និងអកម្មជារូបិយប័ណ្ណផ្សេងពីប្រាក់ដុល្លារត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ជាផ្លូវការរបស់ ធនាគារជាតិនៃកម្ពុជានៅចុងការិយបរិច្ឆេទ។ រាល់ប្រតិបត្តិចំណូល-ចំណាយ រូបិយប័ណ្ណ បរទេសក្រៅពីប្រាក់ដុល្លារ ត្រូវបានប្តូរទៅជាដុល្លារអាមេរិកដោយ ប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ។ ភាពខុសគ្នានៃអត្រាប្តូរប្រាក់ត្រូវ បានទទួលស្គាល់នៅក្នុងគណនីលទ្ធផល ។

( ខ ) **ទ្រព្យសកម្មហិរញ្ញវត្ថុ**

ខេមា ធ្វើការចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនជាប្រភេទដូចតទៅ: (i) សាច់ប្រាក់ និងប្រាក់បញ្ញើរនៅធនាគារ (ii) ការឲ្យខ្ចីចងការ និងគណនីត្រូវទទួល (iii) អចលនទ្រព្យផ្សេងៗ ។

(i) **សាច់ប្រាក់ និងសាច់ប្រាក់បញ្ញើរនៅធនាគារ**

- **សាច់ប្រាក់ និងសាច់ប្រាក់សមមូល**

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់សុទ្ធ, គណនីចរន្ត និងមូលនិធិមានកាលកំណត់ ដែលអាចយកទៅប្រើបាន ក្នុងរយៈពេលតិចជាងមួយខែ។

| | ដុល្លារអាមេរិក/ US$ | ពាន់រៀល/ KHR'000 |
|---|---|---|
| គណនីចរន្តនៅធនាគារជាតិ | 142,600 | 577,957 |
| គណនីចរន្តនៅធនាគារ ANZ Royal | 1,034 | 4190.56 |
| គណនីវិនិយោគនៅធនាគា ANZ | 3,100 | 12564.58 |
| **សរុប** | **146,734** | **594712.94** |

- **ប្រាក់តំកល់តាមច្បាប់នៅធនាគារកណ្តាល**

ប្រាក់តំកល់តាមច្បាប់ រួមមានមូលនិធិបំរុង និងប្រាក់តំកល់នៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមច្បាប់ស្តីពីគ្រឹះស្ថាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប្រាក់តំកល់តាមច្បាប់មិន អាចយកមកប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃទេ ហើយពុំត្រូវបានចាត់ទុក ជាចំណែក នៃសាច់ប្រាក់សមមូល ក្នុងការគណនារបាយការណ៍ចរន្តសាច់ប្រាក់។

(ii) **ការឲ្យខ្ចីចងការ និងបុរេប្រទានចំពោះអតិថិជន**

ឥណទានដែលបានផ្តល់ដោយ ខេមា តាមរយៈការប្រគល់ប្រាក់ ដោយផ្ទាល់ទៅអតិថិជននៅថ្ងៃកំណត់ត្រូវបានចំណាត់ថ្នាក់ជា ការឲ្យខ្ចីចងការ និងបុរេប្រទាន។ ការឲ្យខ្ចីចងការ និងបុរេប្រទាននេះត្រូវបានកត់ត្រាយោងប្រាក់កម្ចីដែលបានបញ្ចេញ។ ការប្រាក់ព្យួរទុកសំដៅទៅការប្រាក់បង្គរលើឥណទានដែលបានបញ្ចេញ។

(iii) **សំវិធានធនលើឥណទានជាប់សង្ស័យ**

សំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានផ្អែកលើសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវបាន ធ្វើឡើងចំពោះហានិភ័យ ជាក់លាក់លើឥណទានទីមួយៗដែលបានវាយតម្លៃ និងចំណាត់ថ្នាក់ជាឥណទានក្រោមជម្មតា, ជាប់សង្ស័យ ឬបាត់បង់ ដោយពុំគិតលើតម្លៃវត្ថុដាក់ធានា (ដោយឡែកតែវត្ថុធានាជាសាច់ប្រាក់)។ ខេមា មិនមានសំវិធានធន ឬឥណទានជាប់សង្ស័យទេ។ សេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា តម្រូវអោយមានការចាត់ថ្នាក់ និងកម្រិតសំវិធានធនដូចតទៅ:

| ចំណាត់ថ្នាក់ | ហួសការកំណត់ | កម្រិតសំវិធានធន |
|---|---|---|
| ក្រោមស្តង់ដារ | -លើសពីសាមសិបថ្ងៃ (៣០ថ្ងៃ) | ១០% |
| ជាប់សង្ស័យ | -លើសពីហុកសិបថ្ងៃ (៦០ថ្ងៃ) (ឥណទានមានកាលកំណត់មិន លើសពី១ឆ្នាំ)<br>-លើសមួយរយប៉ែតសិបថ្ងៃ (១៨០ថ្ងៃ)<br>(ឥណទានមានកាលកំណត់លើសពី១ឆ្នាំ) | ៣០% |
| បាត់បង់ | -លើសពីកៅសិបថ្ងៃ (៩០ថ្ងៃ) (ឥណទានមានកាលកំណត់មិនលើសពី១ឆ្នាំ)<br>- លើសបីរយហុកសិបថ្ងៃ (៣៦០ថ្ងៃ) (ឥណទានមានកាលកំណត់លើសពី១ឆ្នាំ) | ១០០% |

អនុលោមទៅតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ឥណទានហួសកាលកំណត់ត្រូវបានកំណត់ថាជា ចំនួនសរុបនៃប្រាក់ដើម ឬការប្រាក់ដែលហួសកាលកំណត់សង។

(iv) **ចំណូលពីការប្រាក់**

ចំណូលបានមកពីការប្រាក់លើឥណទានត្រូវបានទទួលស្គាល់លើមូលដ្ឋានសាច់ប្រាក់។

(v) **ការកត់ត្រាចំណូលកម្រៃឈ្នួល និងចំណូលដទៃទៀត**

ចំណូលកម្រៃពីកិច្ចសន្យាឥណទាន និងកម្រៃដើងសារត្រូវបានទទួលស្គាល់ក្នុងគណនីលទ្ធផល នៅពេលដែលរាល់ល័ក្ខខ័ណ្ឌនៃ ប្រតិបត្តិការត្រូវបានបំពេញ។ កម្រៃលើសេវា និងកម្រៃលើ ប្រតិបត្តិការត្រូវបានទទួល ស្គាល់ជាចំណូលនៅពេលបានទទួល។

(vi) **អចលទ្រព្យ**

អចលនទ្រព្យត្រូវបានកត់ត្រាតាមតម្លៃដើមដោយដកបន្ថយនូវរំលស់បង្គរ និងការខាតបង់ដោយសារការចុះនៃតម្លៃ។ ដីធ្លីពុំមានអាយុកាលប្រើប្រាស់ទេហើយមិនត្រូវធ្វើរំលស់ទេ ។ តម្លៃដើមរាប់បញ្ចូលចំណាយផ្សេងៗ ដែលទាក់ទងផ្ទាល់នឹងការទិញអចលនទ្រព្យ ។ រាល់ការជួសជុល និងការថែរទាំត្រូវបាន កត់ត្រាក្នុងគណនីលទ្ធផលនៅក្នុងគណនីលទ្ធផល នៅក្នុងកាលបរិច្ឆេទដែលការជួសជុលនិងថែរទាំនោះបានកើតឡើងទាយជួទាន អោយដល់រំលស់ត្រូវបាន គណនាដោយប្រើវិធីសាស្រ្តនិងអត្រារំលស់ដូចខាងក្រោម:

| | | |
|---|---|---|
| - សង្ហារឹម | រំលស់ថយចុះ | ២៥% |
| - កំព្យូទ័រ និងឧបករណ៍ព័ត៌មានវិទ្យា | រំលស់ថយចុះ | ២០ - ៥០% |
| - ទ្រព្យអរូបីយ | រំលស់ថយចុះ | ២៥% |

តម្លៃនៅសល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានពិនិត្យឡើងវិញ និងក្នុងករណី ចាំបាច់ ត្រូវបានធ្វើនិយ័តកម្មនៅរាល់ការិយបរិច្ឆេទបិទបញ្ជី។ ទ្រព្យសកម្មត្រូវបានពិនិត្យដើម្បីកំណត់ការខាតបង់ ដោយសារការចុះនៃតម្លៃក្តីកណាព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរនៃហេតុការណ៍ បង្ហាញឲ្យឃើញថា តម្លៃយោងរបស់វាអាចមិនស្រង់មកវិញបាន។

(vii) **ពន្ធលើប្រាក់ចំណេញ**

ពន្ធលើប្រាក់ចំណេញត្រូវបានគណនាលើមូលដ្ឋាននៃប្រាក់ចំណេញជាប់ពន្ធ ដែលមានការកែតម្រូវលទ្ធផលគណនេយ្យចំពោះ ខ្ទង់ចំណាយមួយចំនួន ( ដូចជា ចំណាយប្រតិបត្តិការ ប្រាក់បៀវត្សបុគ្គលិក, រំលស់លើសឬខ្វះ ។ល។ ) ដោយអនុលោមទៅតាមច្បាប់សារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា។ ពន្ធក្រៅពីពន្ធលើប្រាក់ចំណេញត្រូវបានកត់ត្រាជាចំណាយប្រតិបត្តិការណ៍។

(viii)**ពន្ធលើប្រាក់ចំណេញលើកាលបរិច្ឆេទ**

ពន្ធលើប្រាក់ចំណេញលើការិយបរិច្ឆេទ គឺជាពន្ធដែលរំពឹងថានឹងត្រូវបង់មុនកាលបរិច្ឆេទដោយគណនាតាមអត្រាពន្ធជាធរមាន ឬអត្រាពន្ធដែលគិតថាជាធរមាននៅថ្ងៃបិទបញ្ជី និងដោយរាប់បញ្ចូលនិយ័តកម្មពន្ធត្រូវបង់យោងពីកាលបរិច្ឆេទមុនៗ។

### (ix) ពន្ធយោងទៅការិយបរិច្ឆេទក្រោយ

ពន្ធយោងទៅការិយបរិច្ឆេទក្រោយ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រតារាងតុល្យការទៅលើភាពលំអៀងជាបណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្ម និងអកម្ម ដែលបានរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃដែលបានប្រើក្នុងការគណនាពន្ធ។ តម្លៃដែលបានកំណត់ចំពោះពន្ធយោងទៅការិយបរិច្ឆេទក្រោយ មានមូលដ្ឋានលើការព្យាករណ៍លើការសម្រេចបានឬការទូទាត់ នៃតម្លៃយោងនៃទ្រព្យសកម្ម និងអកម្ម ដោយប្រើអត្រាពន្ធ ដែលបានកំណត់នៅថ្ងៃបិទបញ្ជី។ ពន្ធសកម្មយោងទៅការិយបរិច្ឆេទក្រោយត្រូវបានទទួលស្គាល់ តែក្នុងករណីដែលរំពឹងថា នឹងមានលទ្ធផល ចំណេញជាប់ពន្ធនាពេលអនាគតដើម្បី កាត់កងជាមួយពន្ធសកម្មយោងទៅការិយបរិច្ឆេទក្រោយនោះ។ ពន្ធសកម្មយោងទៅការិយបរិច្ឆេទ ក្រោយត្រូវបានកាត់បន្ថយក្នុងករណី ដែលលែងមានការរំពឹងថា អត្ថប្រយោជន៍ពន្ធនោះអាចនឹងប្រើប្រាស់បានទៀត។

### (x) ការជួលទៅតាមកិច្ចសន្យាប្រតិបត្តិការ

ការទូទាត់ដែលបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃការជួលទៅតាមកិច្ចសន្យាប្រតិបត្តិការណ៍ត្រូវបានកត់ត្រាជាចំណាយស្មើភាគសម្រាប់ កំឡុងពេលនៃកិច្ចសន្យាជួល។

### (xi) ភាគីសម្ព័ន្ធញាត្តិ

ភាគីនីមួយៗត្រូវបានសម្គាល់ជាសម្ព័ន្ធញាត្តិជាមួយគ្នា ល្គឹកណាភាគីណាមួយអាចត្រួតត្រាភាគីមួយទៀត ឬអាចជះឥទ្ធិពលលើភាគីមួយទៀតក្នុងសេចក្តីសម្រេចចិត្ត លើកិច្ចប្រតិបត្តិការណ៍ហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការអាជីវកម្ម។ ក្នុងក្របខ័ណ្ឌនៃច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និយមន័យនៃសម្ព័ន្ធញាត្តិរាប់បញ្ចូលបុគ្គលទាំងឡាយ ដែលកាន់កាប់ ដោយផ្ទាល់ឬដោយប្រយោលនូវដប់ភាគរយយ៉ាងតិចនៃដើមទុន ឬសិទ្ធិបោះឆ្នោត និងរាប់បញ្ចូលបុគ្គលណាដែលចូលរួមក្នុងការ អភិបាល, ដឹកនាំ, ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន។

## ៤. សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា

ស្របតាមបទបញ្ញត្តិនៃប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ ៧-០០-០៦ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ កែតម្រូវដោយ ប្រកាស លេខ ធ ៧-០៦-២០៩ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦ ខេមា ត្រូវរក្សានៅធនាគារជាតិនៃកម្ពុជា នូវប្រាក់តំកល់លក្ខន្តិកៈ ចំនួន៥ភាគរយនៃដើមទុនដោយទទួលកម្រៃការប្រាក់។ ប្រាក់តំកល់លក្ខន្តិកៈនេះ នឹងត្រូវប្រគល់ អោយទៅ ខេមា វិញនៅពេលដែលមានការជំរះបញ្ជីដោយស្ម័គ្រចិត្តដោយពុំមានបញ្ញើប្រាក់ បំណុលនៅសល់។ ប្រាក់តំកល់លក្ខន្តិកៈជាប្រាក់រៀលទទួលបានការប្រាក់ប្រចាំឆ្នាំស្មើនឹង មួយភាគពីរ (១/២) នៃអត្រាការប្រាក់តំកល់ហិរញ្ញប្បទានដែលកំណត់ដោយ ធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយៈ ៦ខែម្តង។ ប្រាក់តំកល់លក្ខន្តិកៈជារូបិយប័ណ្ណបរទេស ទទួលបានកម្រៃការប្រាក់បីភាគប្រាំបី (៣/៨) នៃអត្រា SIBOR ក្នុងរយៈ ៦ខែម្តង។

| | ដុល្លារអាមេរិក/ USD | ពាន់រៀល/ KHR'000 |
|---|---|---|
| ប្រាក់តំកល់តាមច្បាប់នៅធនាគារជាតិ | 17,500 | 70,727 |
| គណនីចរន្តនៅធនាគារជាតិ | 142,600 | 577,958 |
| *សរុប* | **160,100** | **648,885** |

## ៥. សមតុល្យជាមួយធនាគារពាណិជ្ជក្នុងស្រុក

| | ដុល្លារអាមេរិក/ USD | ពាន់រៀល/ KHR'000 |
|---|---|---|
| គណនីចរន្តនៅធនាគារ ANZ Royal | 1,034 | 4,190 |
| គណនីវិនិយោគនៅANZ Royal | 3,100 | 12,565 |

| សរុប | 4,134 | 16,755 |
|---|---|---|

## ៦. ការឲ្យខ្ចីចងការ និងបុរេប្រទានចំពោះអតិថិជន (ការិយបរិច្ឆេទថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំ២០១០)

| | | ដុល្លាអាមេរិក | ពាន់រៀល |
|---|---|---|---|
| ប្រភេទអជីវកម្ម | ចំនួនគណនី | USD | KHR'000 |
| កសិកម្ម | 1 | 1,500 | 6,080 |
| ពាណិជ្ជកម្ម | 17 | 72,299 | 293,028 |
| សេវាកម្ម | 19 | 65,868 | 266,963 |
| ដឹកជញ្ជូន | - | - | - |
| សំណង់ | - | - | - |
| ក្រុមគ្រួសារ | 1 | 665 | 2,695 |
| ផ្សេងៗ | - | - | - |
| សរុប | **38** | **140,332** | **568,766** |

| | ដុល្លាអាមេរិក | ពាន់រៀល |
|---|---|---|
| | USD | KHR'000 |
| (ក) *វិភាគតាមកាលកំណត់សង:* | | |
| ក្នុងកំឡុងពេលមួយខែ | - | - |
| ពីមួយទៅបីខែ | - | - |
| ពីបីខែទៅប្រាំមួយខែ | - | - |
| ពីប្រាំមួយខែទៅដប់ពីរខែ (៦-១២ខែ) | - | - |
| ពីដប់ពីរខែទៅម្ភៃបួនខែ (១២-២៤ខែ) | 140,332 | 568,766 |
| សរុប | **140,332** | **568,766** |

(ខ) *ការវិភាគតាមប្រភេទរូបិយបណ្ណ:*

| | | |
|---|---|---|
| *ដុល្លារអាមេរិក* | 140,332 | 568,766 |
| *ប្រាក់រៀល* | - | - |

**(គ) *វិភាគតាមការស្នាក់នៅ:***

| | | |
|---|---|---|
| *និវាសនជន* | 140,332 | 568,766 |

**(ឃ) *វិភាគតាមសម្ព័ន្ធភាគី:***

| | | |
|---|---|---|
| *ពុំមែនភាគីសម្ព័ន្ធញាត្តិ* | 140,332 | 568,766 |

**(ង) *វិភាគតាមហានីភ័យ:***

| | | |
|---|---|---|
| *ពុំមែនហានីភ័យធំ* | 140,332 | 568,766 |

**(ច) *វិភាគតាមអត្រាការប្រាក់* (*ក្នុងរយៈពេលមួយឆ្នាំ*)**

| | | |
|---|---|---|
| *ឥណទានចំពោះអតិថិជន* | 22.80% | -36.00% |

## ៧. គណនីត្រូវទទួលផ្សេងទៀត

| | *ដុល្លារអាមេរិក/* USD | *ពាន់រៀល/* KHR'000 |
|---|---|---|
| *ការប្រាក់ត្រូវទទួល* | 1,704 | 5,911 |
| *ការទូតទាត់មុន និងប្រាក់តំកល់* | 4,200 | 17,023 |
| *គណនីផ្សេងៗ* | 1,458 | 6,906 |
| ***សរុប*** | **7,362** | **29,840** |

## ៨. អចលនទ្រព្យ

### សំភារៈបរិក្ខារការិយាល័យតាមតម្លៃពិត

| | សង្ហារឹម | កុំព្យូទ័រ និងឧបករណ៍ | ទ្រព្យអរូបីយ | ដុល្លារអាមេរិក USD សរុប | ពាន់រៀល KHR'000 សរុប |
|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី ០១ សីហា ២០១០ | 3,415 | 5,677 | 3,000 | 12,092 | 49,009 |
| ទិញបន្ថែម | 150 | 620 | - | 770 | 3,121 |
| នាថ្ងៃទី ៣១ ធ្នូ ២០១០ | 3,565 | 6,297 | 3,000 | 12,862 | 52,130 |
| **រំលស់បង្គរ** | | | | | |
| នាថ្ងៃទី ៣១ ធ្នូ ២០១០ | (433) | (650) | (313) | (1,396) | (5,657) |
| **តម្លៃពិត** | | | | | |
| នាថ្ងៃទី ៣១ ធ្នូ ២០១០ | **3,132** | **5,647** | **2,687** | **11,466** | **46,473** |

## ៩. ទ្រព្យអកម្មផ្សេងៗ

សម្រាប់បំណាច់ឆ្នាំ២០១០ នេះ ខេមា នៅមានបំណុលមិនទាន់ទូទាត់តែមួយគត់គឺ ពន្ធលើប្រាក់បៀវត្ស សម្រាប់បុគ្គលិក ដែលមានចំនួន ៤០.១០ដុល្លារ និងគិតជាប្រាក់រៀលស្មើនឹង ១៦២,៥២៥ រៀល។

## ១០. សំវិធានធនលើពន្ធ

| | ដុល្លារអាមេរិក USD | ពាន់រៀល KHR'000 |
|---|---|---|
| សមលុត្យនៅដើមការិយបរិច្ឆេទ | - | - |
| សំវិធានធនក្នុងការិយបរិច្ឆេទ | 35 | 141 |
| ពន្ធបានបង់ក្នុងការិយបរិច្ឆេទ | (22) | (89) |
| សមលុត្យនៅចុងការិយបរិច្ឆេទ | 13 | 52 |

## ១១. ដើមទុន

ដើមទុនដែលបានចុះបញ្ជីសរុបចំនួន ៣៥០,០០០.០០ដុល្លារអាមេរិក ដែលស្មើទៅនឹងភាគហ៊ុនសរុបចំនួន ៣,៥០០.០០ ភាគហ៊ុន ដោយក្នុងមួយហ៊ុនមានតម្លៃស្មើ ១០០.០០ ដុល្លារអាមេរិក ។

| | ដុល្លារអាមេរិក USD | ពាន់រៀល KHR'000 |
|---|---|---|
| **ដើមទុនក្នុងឆ្នាំ ២០១០** | | |
| សមតុល្យនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ | 200,000 | 810,600 |
| បង្កើនដើមទុន ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០ | 150,000 | 607,950 |
| ***សមតុល្យនៅថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំ ២០១០*** | **350,000** | **1,418,550** |

## ១២. ចំណូលការប្រាក់

| ប្រភេទចំណូល | ដុល្លារអាមេរិក<br>USD | ពាន់រៀល<br>KHR'000 |
|---|---|---|
| *ចំណូលពីការដាក់ប្រាក់បញ្ញើរនៅធនាគារផ្សេងៗ* | 351 | 1,422 |
| *ចំណូលពីការឲ្យអតិថិជនខ្ចី* | 4,694 | 19,025 |
| *សរុប* | **5,045** | **20,447** |

## ១៣. បៀវត្ស និងសោហ៊ុយបុគ្គលិកដទៃទៀត

| | ដុល្លារអាមេរិក<br>USD | ពាន់រៀល<br>KHR'000 |
|---|---|---|
| *ប្រាក់លាភការសម្រាប់ការប្រជុំក្រុមប្រឹក្សា* | 110 | 446 |
| *ប្រាក់បៀវត្សបុគ្គលិក និងសោហ៊ុយវិជ្ជាជីវៈ* | 10,310 | 41,788 |
| *សរុប* | **10,420** | **42,234** |

## ១៤. ចំណាយប្រតិបត្តិការ

| **ចំណាយប្រតិបត្តិការ** | **ដុល្លារអាមេរិក**<br>**USD** | **ពាន់រៀល**<br>**KHR'000** |
|---|---|---|
| *ចំណាយទឹក និងភ្លើង* | 471 | 1,909 |
| *ជួលអាគារ* | 9,100 | 36,882 |
| *ចំណាយតំឡើង ជួសជុល និងថែទាំ* | 5,003 | 20,276 |
| *ចំណាយទំនាក់ទំនង ការធ្វើដំណើរ និងការផ្សាយពាណិជ្ជកម្ម* | 1,811 | 7,340 |
| *សោហ៊ុយអាជ្ញាប័ណ្ណ និងសេវាផ្នែកច្បាប់ផ្សេងៗ* | 518 | 2,098 |
| *ពន្ធប៉ាតង់ និងអាករដទៃទៀត* | 1,105 | 4,480 |
| *សំភារៈផ្គត់ផ្គង់ការិយាល័យ* | 1,075 | 4,356 |
| *ចំណាយផ្សេងៗ* | 240 | 973 |
| ***សរុប*** | **19,323** | **78,314** |

## ១៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

*គោលការណ៍ណែនាំ និងគោលនយោបាយបានអនុម័តដោយ ខេមា ដើម្បីចាត់ចែងនូវហានិភ័យដែលកើតឡើងក្នុងសកម្មភាព អាជីវកម្មមានដូចខាងក្រោម៖*

### (ក) ហានិភ័យប្រតិបត្តិការ

*ការខាតបង់ពីហានិភ័យប្រតិបត្តិការ ដែលអាចបណ្តាលមកពីកង្វះខាត ឬដំណើរការមិន បានល្អនៃការគ្រប់គ្រងផ្ទៃក្នុង ធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រង ត្រូវបានទប់ស្កាត់តាមរយៈ ការបង្កើតនូវការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឲ្យបានត្រឹមត្រូវ ពីសកម្មភាពអាជីវកម្មដែលធ្វើឡើងដោយអង្គភាពគ្រប់គ្រង និងអង្គភាពគាំទ្រដែលជា អង្គភាពឯករាជ្យពីការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ។*

*ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការ តម្រូវឲ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឲ្យបាន ច្បាស់លាស់។ គោលការណ៍ និងវិធានការណ៍ត្រួតពិនិត្យផ្ទៃក្នុងនីមួយៗត្រូវបានអនុវត្ត។ វិធានទាំងនេះរួមមានការបង្កើតនូវការចុះ ហត្ថលេខាតាមតួនាទី ការកំណត់ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនិតិវិធី និងឯកសារសំអាង។ វិធានទាំងនេះត្រូវត្រួតពិនិត្យឡើងវិញជានិច្ចកាលដើម្បីទប់ស្កាត់ហានិភ័យប្រតិបត្តិការ អាជីវកម្មរបស់ ខេមា។*

( **ខ** ) **ហានិភ័យទីផ្សារ**

(i) **ហានិភ័យរូបិយប័ណ្ណបរទេស**

*ហានិភ័យលើរូបិយប័ណ្ណសំដៅទៅលើ ហានិភ័យនៃការប្រែប្រួលចុះឡើង នៃឧបករណ៍ហិរញ្ញវត្ថុដែលកើតឡើងពីការផ្លាស់ប្តូរក្នុង អត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស។ ខេមា ពុំមានហានិភ័យជាសារៈសំខាន់លើរូបិយប័ណ្ណទេ ដោយមូលហតុ ខេមា មានប្រតិបត្តិការភាគច្រើនជាប្រាក់ដុល្លារអាមេរិក។ វត្តមាននៃប្រាក់ដុល្លារអាមេរិក ក្នុងប្រតិបត្តិការអាជីវកម្មជាទម្លាប់ធម្មតានៅកម្ពុជា ដោយសារប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណ ទូរទាត់ដែលគេនិយមប្រើប្រាស់នៅកម្ពុជា។*

(ii) **ហានិភ័យអត្រាការប្រាក់**

*ហានិភ័យអត្រាការប្រាក់ សំដៅទៅការខាតបង់នូវចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងទ្រព្យអកម្ម។ ហានិភ័យលើអត្រាការប្រាក់ត្រូវបានគ្រប់គ្រងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់ទៅលើចំណូល ពីការបណ្តាក់ទុន តម្លៃទីផ្សារ តម្លៃដើមនៃមូលនិធិ និង តាមរយៈការវិភាគ តាមចន្លោះប្រែប្រួលអត្រាការប្រាក់។ សក្តានុពលនៃការធ្លាក់ចុះ នូវចំណូលអត្រាការប្រាក់សុទ្ធពីការប្រែលប្រួលអត្រាការប្រាក់ដែល ខុសប្រក្រតីត្រូវបានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតហានិភ័យដែលកំណត់ថាអាចទទួលយកបាន ។ ថ្នាក់ដឹកនាំមានការជឿជាក់ថា ជំហររបស់ ខេមា មានលក្ខណៈសមស្របដើម្បីកាត់បន្ថយហានិភ័យលើ អត្រាការប្រាក់។*

( **គ** ) **ការគ្រប់គ្រងមូលធន**

*ខេមាទទួលស្គាល់តម្រូវការនៃតុល្យភាពរវាង ប្រសិទ្ធភាព, ភាពបត់បែន, និងភាពគ្រប់គ្រាន់នៅពេលកំណត់ចំនួនដើមទុនត្រូវបំពេញ និងនៅពេលរៀបចំគំរោងគ្រប់គ្រងមូលធន។ ខេមា វិភាគអំពីតម្រូវ*

*ការទាំងនេះតាមរយៈការវាយតម្លៃផ្ទៃក្នុងលើភាព គ្រប់គ្រាន់នៃដើមទុន ដែលមានលក្ខណៈចម្បងដូចតទៅ (ក) ការពិចារណាលើស្ថានភាពសេដ្ឋកិច្ច និងបទបញ្ញាត្តិស្តី អំពីដើមទុនអប្បបរមា ដែលបានបញ្ញាត្តិដោយធនាគារជាតិនៃកម្ពុជា, (ខ) ការពារនិរន្តភាពនៃ ដំណើរការអាជីវកម្មដើម្បីឲ្យខេមា មានលទ្ធភាពផ្តល់ភាគលាភទៅភាគទុនិក និងផ្តល់អត្ថប្រយោជន៍ទៅភាគីពាក់ព័ន្ធ និង (គ) រក្សានូវមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រការអភិវឌ្ឍន៍ របស់អាជីវកម្ម។*

ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

CAMMA MICROFINANCE LIMITED

# ឱកាសជាសហគ្រន









**អាសយដ្ឋាន**

ផ្ទះលេខ ៤៩ ផ្លូវ ២៩៤ សង្កាត់បឹងកេងកង ១   ខណ្ឌចំការមន រាជធានីភ្នំពេញ។

ទូរស័ព្ទលេខ: ០២៣ ៩៩៦ ៩៣៦

Email: camma. mfi@gmail.com